# តើអ្នកដឹងអ្វីខ្លះពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ?

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

JUSTICE INITIATIVE

គម្រោងយុត្តិធម៌សង្គមសេរី

សហការជាមួយ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា




**ទីនេះ** គឺជាទីតាំងរបស់តុលាការកាត់ទោស
មេដឹកនាំខ្មែរក្រហម ដែលស្ថិតនៅ
ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ
ខ័ណ្ឌដង្កោ ភ្នំពេញ កម្ពុជា



រូបថតៈ អនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង មជ្ឈមណ្ឌលឯកសារកម្ពុជា

# តើមានរឿងអ្វីខ្លះ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម?

**រូបភាព ៖**

រូបភាពទី ១៖ បង្ហាញពីប្រជាជនកំពុងត្រូវពួកខ្មែរក្រហមជម្លៀសចេញពីទីក្រុង
រូបភាពទី ២៖ បង្ហាញអំពីការធ្វើទំនប់ក្នុងរបបខ្មែរក្រហម
រូបភាពទី ៣៖ បង្ហាញពីសាកសពនៅក្នុងគុកទួលស្លែង ភ្លាមៗ ក្រោយពីរបបខ្មែរក្រហមដួលរលំ
រូបភាពទី ៤៖ បង្ហាញពីលលាដ៏ក្បាលដែលត្រូវបានគេរកឃើញក្រោយរបបខ្មែរក្រហម

**អត្ថបទ ៖**

- រូបភាពខាងលើនេះ បង្ហាញពីរឿងរ៉ាវដ៏ជូរចត់ ដែលប្រជាជនខ្មែរមួយចំនួនបានជួបប្រទះ នារបបខ្មែរក្រហម ឬ ហៅថា របប ប៉ុល ពត ឬ ហៅម្យ៉ាងទៀតថា "**របបកម្ពុជាប្រជាធិបតេយ្យ**"។
- មានប្រជាជនមួយចំនួនទៀត ក៏បានជួបប្រទះនូវរឿងរ៉ាវដទៃផ្សេងទៀតដែរ ប៉ុន្តែយើងអត់មានរូបថតដើម្បីបង្ហាញ លោក អ្នក ដូចជា ភាពអត់ឃ្លាន ការធ្វើទារុណកម្ម និងការបង្ខំឱ្យរៀបការ ជាដើម ។ល។

រូបថត៖ អនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង មជ្ឈមណ្ឌលឯកសារកម្ពុជា



រូបថតៈ អនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងពតិមាន

# តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានកើតឡើងយ៉ាងដូចម្តេច?

**រូបភាព ៖**

នេះគឺ ជារូបភាពនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងភាគីកម្ពុជាដែលមាន **ឯកឧត្តម សុខ អាន** ជាតំណាង និង ភាគីអង្គការសហប្រជាជាតិដែលមាន **លោក ហែន កូរែល** ជាតំណាង។

**អត្ថបទ ៖**

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបង្កើតឡើងដោយច្បាប់កម្ពុជា និង កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ដែលកិច្ចព្រមព្រៀងនេះចែងអំពីការងាររបស់ភាគីទាំងពីរ នៅក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

រូបថត៖ អនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងពត៌មាន


Court Room
Salle d' Audience

# អ្វីទៅជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

**រូបភាព ៖**

នេះ គឺ ជារូបអាគារតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

**អត្ថបទ ៖**

**អ្វីទៅជាតុលាការ?**

តុលាការ គឺជាកន្លែងដោះស្រាយជំលោះដោយស្វែងរកអ្នកប្រព្រឹត្តខុស និងត្រូវហើយអ្នកដែលប្រព្រឹត្តខុស ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

**ចុះអ្វីទៅជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?**

- តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាតុលាការដែលមានលក្ខណៈពិសេសខុសពី តុលាការធម្មតា ដោយសារចំនុចសំខាន់មួយចំនួនដូចជា តុលាការនេះមានការចូលរួមពីអន្តរជាតិ និង កាត់ទោសតែទៅលើបុគ្គលមួយចំនួនដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។
- ជាទូទៅប្រជាជនហៅតុលាការនេះថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬ តុលាការខ្មែរក្រហម ប៉ុន្តែតាមពិតតុលាការនេះមានឈ្មោះថា **"អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"** ។



# តើតុលាការនឹងកាត់ទោសបុគ្គលដែលបានប្រព្រឹត្តបទល្មើសអ្វីខ្លះ?

**រូបភាព:**

នៅក្នុងរូបភាពទាំងនេះ បង្ហាញលោកអ្នកអំពីបទល្មើសធ្ងន់ធ្ងរដែលស្ថិតនៅក្នុងច្បាប់ជាតិ ដូចជា:

រូបភាពទី ១ : ការបង្ខំឱ្យព្រះសង្ឃសឹកដែលនេះ គឺជាឧទាហរណ៍មួយបែបនៅក្នុងបទល្មើសស្តីពី ការធ្វើទុក្ខបុកម្នេញខាងសាសនា

រូបភាពទី ២ : ការនាំអ្នកទោសទៅសំលាប់នៅរណ្តៅសាកសពរួម ដែលនេះគឺជាឧទាហរណ៍មួយបែបនៅក្នុងការសំលាប់ ឬ ហៅថា អំពើមនុស្សឃាដ

រូបភាពទី ៣ : ការធ្វើទារុណកម្មដោយចងខ្សែព្យួរឡើងលើ ដែលនេះគឺជាឧទាហរណ៍ មួយបែបនៃបទល្មើសដែលមានឈ្មោះថា អំពើទារុណកម្ម

**អត្ថបទ:**

តុលាការនឹងកាត់ទោសបុគ្គលដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដោយយោងតាមច្បាប់ជាតិ និង ច្បាប់អន្តរជាតិ បទល្មើសនៅក្នុងច្បាប់ជាតិមានដូចជា:

- អំពើមនុស្សឃាដ
- ការធ្វើទារុណកម្ម
- ការធ្វើទុក្ខបុកម្នេញខាងសាសនា

ច្បាប់អន្តរជាតិមានពាក្យស្មុគស្មាញ ពិបាកយល់ ។ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យទាំងនេះនៅតែមានសារៈសំខាន់សំរាប់តុលាការ ។ បទល្មើសមួយចំនួននៅក្នុងច្បាប់អន្តរជាតិ ដែលតុលាការនឹងប្រើប្រាស់ មានដូចជា:

- ឧក្រិដ្ឋកម្មសង្គ្រាម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ
- អំពើប្រល័យពូជសាសន៍ ។



## តុលាការនេះមានអំណាចកាត់ទោសតែបុគ្គលមួយចំនួន ហើយតើបុគ្គលមួយចំនួននោះ ជាអ្នកណាខ្លះ?

**រូបភាព:**

នេះ គឺជារូបភាពឧទាហរណ៍មួយដែលបង្ហាញអំពីការដឹកនាំនៅថ្នាក់លើ ទៅថ្នាក់បន្តបន្ទាប់ក្នុងរបបខ្មែរក្រហម ។ ការដឹកនាំក្នុងរបបនោះ យើងមិនដឹងថាមានមនុស្សចំនួន ប៉ុន្មាននាក់នោះទេ?

**អត្ថបទ:**

**ឥឡូវតើអ្នកអាចប្រាប់យើងបានទេ ថាតើនៅថ្នាក់ណាដែលតុលាការគួរតែកាត់ទោស?**

- តុលាការនេះនឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ តុលាការនេះនឹងមិនកាត់ទោសសាច់ញាតិរបស់ពួកគេទេ ។

- យើងនៅមិនទាន់ដឹងនៅឡើយទេថា អ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬ ជនទាំងឡាយដែលទទួលខុសត្រូវ ខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ មានតែតុលាការទេជាអ្នកសំរេច ។ បើតាមអ្នកនាំពាក្យរបស់តុលាការបាននិយាយថា ដោយយោងតាមថវិកាដែលគ្រោងទុករបស់តុលាការ ប្រហែលជាមានពី ៥ នាក់ ទៅ ១០ នាក់ ។

- តុលាការនឹងកាត់ទោស អ្នកដែលនៅរស់តែប៉ុណ្ណោះ មិនកាត់ទោសអ្នកដែលបានស្លាប់ទៅហើយនោះទេ ដូចជា ប៉ុល ពត តា ម៉ុក ជាដើម ។


១៧ មេសា ១៩៧៥
៦ មករា ១៩៧៩

# តើតុលាការនឹងកាត់ទោសបទល្មើសធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងនៅចន្លោះពេលណា?

**រូបភាព:**

រូបភាពនេះបង្ហាញអំពីអំឡុងពេលនៃបទល្មើសធ្ងន់ធ្ងរដែលតុលាការមានអំណាចយកមកកាត់ទោស។

- ថ្ងៃទី ១៧ មេសា ១៩៧៥ គឺជាថ្ងៃដែលកងទ័ពខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ។
- ថ្ងៃទី ៦ មករា ១៩៧៩ គឺជាថ្ងៃចុងក្រោយ ដែលកងទ័ពខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ។

**អត្ថបទ:**

តុលាការនេះមានអំណាចកាត់ទោសតែបទល្មើសធ្ងន់ធ្ងរដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។




រូបថត: អនុញ្ញាតឱ្យប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា

# តើតុលាការនេះមានសមាសភាពយ៉ាងដូចម្តេច?

**រូបភាព:**

នេះ គឺជាសមាសភាពនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

**អត្ថបទ:**

**តើតុលាការនេះមានសមាសភាពយ៉ាងដូចម្តេច? ហើយមានប៉ុន្មានថ្នាក់?**
តុលាការនេះមានតែ ២ ថ្នាក់ប៉ុណ្ណោះ គឺសាលាដំបូង និង តុលាការកំពូល ។ នៅសាលាដំបូងមានចៅក្រម ៥ នាក់ (ខ្មែរ ៣ នាក់ និង បរទេស ២ នាក់) ឯតុលាការកំពូលមានចៅក្រម ៧ នាក់ (ខ្មែរ ៤ នាក់ និង បរទេស ៣ នាក់) ។

ក្រៅពីតុលាការទាំងពីរថ្នាក់នេះ នៅមាន

- ការិយាល័យសហព្រះរាជអាជ្ញាដែលមានខ្មែរម្នាក់ និង បរទេសម្នាក់
- ការិយាល័យសហចៅក្រមស៊ើបអង្កេត ខ្មែរម្នាក់ និង បរទេសម្នាក់
- ក្រៅពីនេះក៏មានអង្គបុរេជំនុំជម្រះ ដែលត្រូវបានបង្កើតឡើងសំរាប់ដោះស្រាយការខ្វែងយោបល់គ្នារវាងព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញា រវាងចៅក្រមស៊ើបអង្កេត និង ចៅក្រមស៊ើបអង្កេតផងដែរ ។
- ហើយក៏មានការិយាល័យរដ្ឋបាលដែលមានខ្មែរម្នាក់ ជាប្រធាន និង បរទេសម្នាក់ជាអនុប្រធាន ។

រូបថត: អនុញ្ញាតឱ្យប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា



# តើសហព្រះរាជអាជ្ញាមានតួនាទីធ្វើអ្វីខ្លះ?

**រូបភាព:**

បង្ហាញពីសហព្រះរាជអាជ្ញា ហៅជាសាមញ្ញថា អ្នកចោទប្រកាន់ មានខ្មែរ ម្នាក់ បរទេស ម្នាក់ ធ្វើការចោទប្រកាន់ជនណាម្នាក់ ដោយផ្អែកលើភស្តុតាង ។ យើងនៅមិនទាន់ដឹងទេថា នរណាខ្លះដែលសហព្រះរាជអាជ្ញានឹងចោទប្រកាន់ ដូចនេះហើយ បានជាយើងគូររូបជាស្រមោលខ្មៅ ។

**អត្ថបទ:**

សហព្រះរាជអាជ្ញាមានតួនាទី:

- ធ្វើការស៊ើបអង្កេតដើម្បីប្រមូលភស្តុតាង ដែលមានដូចជា ឯកសារ រណ្តៅសាកសព និង ស្វែងរកសាក្សី ជាដើម ។
- ធ្វើការចោទប្រកាន់ ជនណាម្នាក់ ។
- បង្ហាញភស្តុតាងនៅពេលជំនុំជម្រះ ។

យើងក៏សុំបញ្ជាក់ផងដែរថា សហព្រះរាជអាជ្ញា បានចាប់ផ្តើមការងាររបស់ខ្លួន ចាប់តាំងពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦ មកម្ល៉េះ ។



# តើសហចៅក្រមស៊ើបអង្កេតមានតួនាទីធ្វើអ្វីខ្លះ?

**រូបភាព:**

នៅក្នុងរូបភាពនេះបង្ហាញពីសហចៅក្រមស៊ើបអង្កេត ២ នាក់ ខ្មែរ ម្នាក់ និង បរទេសម្នាក់។ សហចៅក្រមស៊ើបអង្កេតម្នាក់កំពុងសាកសួរទៅកាន់សាក្សី និង ម្នាក់ទៀត កំពុងថតរូប រណ្តៅសាកសព។

**អត្ថបទ:**

- សហចៅក្រមស៊ើបអង្កេតមាន ២ នាក់ ខ្មែរម្នាក់ បរទេសម្នាក់ ទទួលខុសត្រូវរួមគ្នាលើការងារស៊ើបអង្កេត ។
- ក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនយល់ស្រប នឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា នោះ សហចៅក្រមស៊ើបអង្កេត មានអំណាចលើកលែងការចោទប្រកាន់បាន ។



# អ្វីទៅជាជនជាប់ចោទ?

**រូបភាព:**

រូបភាពនេះបង្ហាញពីជនជាប់ចោទត្រូវបានចាប់ខ្លួន

**អត្ថបទ:**

- ជនជាប់ចោទ ជាជនដែលត្រូវបានចោទប្រកាន់ ដោយសហព្រះរាជអាជ្ញា
- ជនជាប់ចោទអាចនឹងត្រូវចាប់ខ្លួន ហើយឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំឡើងតុលាការ ក្នុងករណីដែលជននោះ អាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត ឬ រត់គេចខ្លួន ។

ទោះបីជា ជនជាប់ចោទត្រូវបានឃុំខ្លួនរង់ចាំការកាត់ទោស ឬ មិនស្ថិតក្នុងការឃុំខ្លួនក៏ដោយ ពួកគេនៅតែជាមនុស្សគ្មានទោស ព្រោះតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។



# តើជនជាប់ចោទមានសិទ្ធិពឹងពាក់មេធាវីដែរ ឬទេ?

**រូបភាព:**

រូបភាពនេះ បង្ហាញពីជនជាប់ចោទកំពុងពិភាក្សា ជាមួយមេធាវីរបស់ខ្លួន នៅក្នុងមន្ទីរឃុំឃាំង។

**អត្ថបទ:**

យោងតាមច្បាប់ ជនជាប់ចោទមានសិទ្ធិពឹងពាក់មេធាវី ដើម្បីការពារក្តីរបស់ខ្លួន។
ក្នុងករណីដែលជនជាប់ចោទក្រីក្រ មិនអាចពឹងពាក់មេធាវីបាន ជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីមានសមត្ថភាព ដោយឥតគិតថ្លៃ ។



# តើការជំនុំជម្រះនៅសាលាដំបូងធ្វើឡើងយ៉ាងដូចម្តេច?

**រូបភាព:**

រូបភាពនេះបង្ហាញពីការជំនុំជម្រះនៅសាលាដំបូងដែលមានចៅក្រម ៥ នាក់ អង្គុយនៅខាងមុខ និង មានសហព្រះរាជអាជ្ញា ២ នាក់ ក្នុង សំលៀកបំពាក់រូបពណ៌ក្រហមនៅម្ខាង និង នៅផ្នែកម្ខាងទៀតជាមេធាវីជនជាប់ចោទ និង ជនជាប់ចោទអង្គុយនៅពីខាងក្រោយ។ នៅចំកណ្តាល ពីមុខចៅក្រម គឺជាសាក្សីដែលឡើងរៀបរាប់នូវហេតុការណ៍ ដែលខ្លួនបានឃើញ។ ហើយចំណែកឯមនុស្ស ដែលអង្គុយនៅខាងក្រោម គឺជាអ្នកដែល ចូលរួមស្តាប់ការជនុំជម្រះក្តី។

**អត្ថបទ:**

ជាធម្មតា ការជំនុំជម្រះធ្វើឡើងជាសាធារណៈមានន័យថា ប្រជាជនគ្រប់រូបអាចចូលរួមមើល និង ស្តាប់ការជំនុំជម្រះបាន ។ តែក្នុងករណីមួយចំនួនតូច ចៅក្រមអាចសំរេចថា មិនអនុញ្ញាតឱ្យមានវត្តមានសាធារណជន ដើម្បីការពារសុវត្ថិភាពរបស់សាក្សី ។

នៅក្នុងការជំនុំជម្រះ ចៅក្រមជំនុំជម្រះមានតួនាទីៈ

- ដឹកនាំការជំនុំជម្រះ
- ពិនិត្យមើលភស្តុតាងដែលលើកឡើងដោយ សហព្រះរាជអាជ្ញា និង ភស្តុតាងដែលលើកឡើងដោយមេធាវីជនជាប់ចោទ
- ស្តាប់ការលើកឡើងតាមផ្លូវច្បាប់របស់ សហព្រះរាជអាជ្ញា និង មេធាវីជនជាប់ចោទ



# តើនៅសាលាដំបូងចៅក្រមសំរេចសេចក្ដីយ៉ាងដូចម្ដេច?

**រូបភាព:**

**នៅក្នុងរូបភាពនេះ តើមានចៅក្រមទាំងអស់ប៉ុន្មាននាក់? ខ្មែរប៉ុន្មាននាក់? បរទេសប៉ុន្មាននាក់?**

- នៅក្នុងរូបភាពនេះមានចៅក្រមទាំងអស់ ៥ នាក់ ចៅក្រមខ្មែរ ៣ នាក់ និង ចៅក្រមបរទេស ២ នាក់ ។

**តើមានចៅក្រមប៉ុន្មាននាក់សំរេចថាជនជាប់ចោទមានទោស? ហើយចៅក្រមប៉ុន្មាននាក់សំរេចថាជាប់ចោទគ្មានទោស?**

- រូបភាពនេះបង្ហាញពីចៅក្រម ៣ នាក់ បានសំរេចឱ្យ ជនជាប់ចោទមានទោស ឯចៅក្រម ២ នាក់ទៀតសំរេចឱ្យជនជាប់ចោទគ្មានទោស ។

**អត្ថបទ:**

- ដើម្បីសំរេចថាជនជាប់ចោទមានទោស ចៅក្រមម្នាក់ៗត្រូវគិតឱ្យប្រាកដក្នុងចិត្តថា ជនជាប់ចោទពិតជាបានប្រព្រឹត្តខុសច្បាប់ ។
- នៅសាលាដំបូងដើម្បីសំរេចសេចក្ដីថា ជនជាប់ចោទមានទោសតំរូវឱ្យមានការសំរេចគាំទ្រ ពីចៅក្រមយ៉ាងតិច ៤ នាក់ ក្នុងនោះយ៉ាងហោចណាស់មានម្នាក់ជាបរទេស ។
- ដូច្នេះ តើនៅក្នុងរូបភាពនេះ ជនជាប់ចោទមានទោស ឬ គ្មានទោស?

ជនជាប់ទោសគ្មានទោស ព្រោះមានតែចៅក្រម ៣ នាក់ទេ ដែលសំរេចថាមានទោស ។ នេះគ្រាន់តែជារូបភាពឧទាហរណ៍មួយតែប៉ុណ្ណោះ ។



# តើការជំនុំជម្រះនៅសាលាដំបូងខុសគ្នាពីការជំនុំជម្រះនៅតុលាការកំពូលយ៉ាងដូចម្ដេច?

**រូបភាព:**

នៅក្នុងរូបភាពនេះបង្ហាញពីការជំនុំជម្រះ ដូចសាលាដំបូងដែរ តែចៅក្រមមានចំនួន ៧ នាក់ ។

**អត្ថបទ:**

**ចំនុចដូចគ្នា**

- តុលាការកំពូលមានទីតាំងតែមួយដូចសាលាដំបូងដែរ ។
- ជាធម្មតាការជំនុំជម្រះនៅតុលាការកំពូលធ្វើឡើងជាសាធារណៈដូចសាលាដំបូងដែរ ។

**ចំនុចខុសគ្នា**

- តុលាការកំពូលមានចៅក្រម ៧ នាក់ ឯសាលាដំបូងមានចៅក្រម ៥ នាក់ ។
- តុលាការកំពូល អាចនឹងជំនុំជម្រះក្រោយ សាលាដំបូងជំនុំជម្រះរួចហើយ ។
- ចៅក្រមជំនុំជម្រះនៅតុលាការកំពូល មានអំណាចធ្វើសេចក្ដីសំរេចជាចុងក្រោយ ថាតើជនជាប់ចោទមានទោស ឬ ក៏គ្មានទោស ។



# តើនៅតុលាការកំពូលចៅក្រមសំរេចសេចក្តីយ៉ាងដូចម្តេច?

**រូបភាព:**

**នៅក្នុងរូបភាពតើមានចៅក្រមទាំងអស់ប៉ុន្មាននាក់? ខ្មែរប៉ុន្មាននាក់? បរទេសប៉ុន្មាននាក់?**

- នៅក្នុងរូបភាពនេះមានចៅក្រម ៧ នាក់ ខ្មែរ ៤ នាក់ និង ចៅក្រមបរទេស ៣ នាក់ ។

**តើមានចៅក្រមប៉ុន្មាននាក់សំរេចថាជនជាប់ចោទមានទោស? ហើយចៅក្រមប៉ុន្មាននាក់សំរេចថាជាប់ចោទគ្មានទោស?**

- រូបភាពនេះបង្ហាញពីចៅក្រម ៥ នាក់ បានសំរេចឱ្យជនជាប់ចោទមានទោស ឯចៅក្រម ២ នាក់ទៀតសំរេចថា ជនជាប់ចោទគ្មានទោស។

**អត្ថបទ:**

- ដើម្បីសំរេចថាជនជាប់ចោទមានទោស ចៅក្រមម្នាក់ៗត្រូវគិតឱ្យប្រាកដក្នុងចិត្តថា ជនជាប់ចោទពិតជាបានប្រព្រឹត្តខុសច្បាប់ ។
- ក្នុងការសំរេចសេចក្តីនៅតុលាការកំពូល ដើម្បីកំណត់ថាជនជាប់ចោទមានទោស តំរូវឱ្យមានការសំរេចគាំទ្រពីចៅក្រម យ៉ាងតិច ៥ នាក់ ក្នុងនោះយ៉ាងហោចណាស់ ម្នាក់ជាបរទេស ។ នេះ គឺជាសេចក្តីសំរេចចុងក្រោយ បិទផ្លូវតវ៉ា ។

**ដូច្នេះ តើនៅក្នុងរូបភាពនេះ ជនជាប់ចោទមានទោស ឬ គ្មានទោស?**

- ជនជាប់ចោទ មានទោសពីព្រោះ ចៅក្រម ៥ នាក់ សំរេចថា មានទោស។ នេះគ្រាន់តែ ជារូបភាពឧទាហរណ៍មួយតែប៉ុណ្ណោះ។


រដ្ឋ

# តើជនជាប់ចោទត្រូវទទួលទោសបែបណា បើតុលាការរកឃើញថាមានកំហុស?

**រូបភាព:**

រូបភាពទី ១: បង្ហាញពីការដាក់គុក
រូបភាពទី ២: បង្ហាញថាគ្មានទោសប្រហារជីវិត
រូបភាពទី៣: បង្ហាញពីទ្រព្យសម្បត្តិដែលរឹបអូសបាន ប្រគល់ជូនរដ្ឋ។

**អត្ថបទ:**

- នៅក្នុងករណីដែលចៅក្រម រកឃើញថាជនជាប់ចោទមានកំហុសនោះ ពួកគេអាចនឹងទទួលទោសជាប់គុក ចាប់ពី ៥ ឆ្នាំ រហូតដល់មួយជីវិត។
- លើសពីនេះទៅទៀត ចៅក្រមក៏អាចសំរេចរឹបអូសទ្រព្យសម្បត្តិ ដែលមានដូចជា ដី ផ្ទះ លុយ ឡាន ជាដើម ដែលទទួលបានដោយខុសច្បាប់ ឬ ក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ។
- នៅប្រទេសកម្ពុជា គ្មានទោសប្រហារជីវិតទេ។
- អ្នកទោសមិនត្រូវបានគេធ្វើទារុណកម្មឡើយ។



## តើអ្នកគិតដូចម្តេច ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ?

សូមតាមដាន និង ពិភាក្សាពីដំណើរការតុលាការនេះទាំងអស់គ្នា !

...បន្ទាប់មក លោក-អ្នកអាចធ្វើការវាយតំលៃចំពោះតុលាការនេះដោយសេរី !